គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

( TSTD — ADB TA 7305-CAM )

# បច្ចេកទេសដាំដំណាំបន្លែ



## ម្ទេស

គ្រាប់ពូជល្អ   ទិន្នផលខ្ពស់ល្អ

# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD) ជាគម្រោងជំនួយបច្ចេកទេស ដែលផ្តល់សហ-ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្ត ដោយរដ្ឋាភិបាលហ្វាំងឡង់ មូលនិធិដៃគូអ៊ី-អាស៊ី និងចែករំលែកពុទ្ធិនៃសាធារណរដ្ឋកូរ៉េ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ រាជរដ្ឋាភិបាលកម្ពុជា ចូលរួមបដិភាគមិនមែនជាថវិកា (ធនធានមនុស្ស ការិយាល័យបំពេញការងារ...) សម្រាប់អនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ី ជាអ្នកចាត់ចែងប្រតិបត្តិការផ្ទាល់ ជំនួសមុខឲ្យម្ចាស់ជំនួយ ។ គម្រោង កំពុងធ្វើការសាក ល្បងបង្ហាញបច្ចេកវិទ្យាកសិកម្ម និង ផ្តល់សេវាព័ត៌មានជនបទ ដើម្បីបង្កើន និង ពង្រីកប្រាក់ប្រភពចំណូលរបស់គ្រួសារកសិករខ្នាតតូច ក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។

គម្រោងបានអនុវត្តកម្មវិធីធ្វើបង្ហាញបច្ចេកវិទ្យាផលិតកម្មដំណាំបន្លែ ក្នុងខេត្តកំពង់ចាម និង ខេត្តកំពង់ធំ ដោយសហការជាមួយ ក្រុមហ៊ុនគ្រាប់ពូជបន្លែ អ៊ីស្ត វេស្ត ស៊ីដ អ៊ិនធើណេសិនណល (East West Seed International) ក្នុងរូបភាពកិច្ចសហការភាពជាដៃគូរសាធារណៈ-ឯកជន ។ អ្នកបច្ចេកទេសរបស់ក្រុមហ៊ុន បានសហការជាមួយមន្ត្រីកសិកម្ម នៅតាមមូលដ្ឋានក្នុងខេត្តទាំងពីរ បានអនុវត្តកម្មវិធីធ្វើបង្ហាញ និងបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មបន្លែ ដោយប្រើវិធីសាស្ត្របង្រៀនឱ្យធ្វើអនុវត្តជាក់ស្តែង (សាលារៀនបន្លែកសិករ) ជាជំហានៗ តាមដំណាក់កាលលូតលាស់ ពេញមួយវគ្គដំណាំ។

សៀវភៅណែនាំបច្ចេកទេសកសិករ ស្តីពី *បច្ចេកទេសដាំម្ទេស* នេះ បានរៀបចំឡើងដើម្បីផ្តល់នូវចំណេះដឹង និង ចំណេះធ្វើជាក់ស្តែង ដល់គ្រួសារកសិករ ស្តីពី ការដាំម្ទេស តាមបច្ចេកទេសថ្មី ដែលអាចដាំ បានគ្រប់រដូវពេញមួយឆ្នាំ។ បច្ចេកទេសថ្មីនេះ ជួយគ្រួសារកសិករ ឲ្យមានប្រភពចំណូលថ្មី ជាប្រចាំបន្ថែមមួយទៀត ដោយប្រើប្រាស់ឱ្យកាន់តែអស់លទ្ធភាពនូវធនធានដី-ទឹក និង ធនធានផ្សេងទៀតដែលគ្រួសារមាន ។

ខ្លឹមសារក្នុងសៀវភៅណែនាំបច្ចេកទេសនេះ បានរៀបចំឡើងដោយក្រុមអ្នកបច្ចេកទេសរបស់គម្រោងនិងរបស់ ក្រុមហ៊ុនគ្រាប់ពូជបន្លែ អ៊ីស្ត វ៉េស្ត ស៊ីដ សម្រាប់កសិករ ដោយផ្អែកលើជំហានអនុវត្តជាក់ស្តែង និង បទពិសោធន៍ ទទួលបានជោគជ័យក្នុងការដាំដំណាំនេះ រយៈពេលពីររដូវកន្លងមក នៅក្នុងខេត្តទាំងពីរ ។

ការអនុវត្តកម្មវិធីធ្វើបង្ហាញ និងបណ្តុះបណ្តាល ស្តីពី ការដាំដំណាំម្ទេស តាមបច្ចេកទេសថ្មីនេះ អាចទទួលបានជោគជ័យ ដោយសារមានការគាំទ្រជាប់ជាបន្ត ពីថ្នាក់ដឹកនាំ និង បុគ្គលិកក្រុមទីប្រឹក្សាគម្រោង ពី លោកប្រាក់ ថាវអមិដា ប្រធានសម្របសម្រួលគម្រោង TSTD និង ជាអគ្គលេខាធិការរង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ពីមន្ទីរកសិកម្មខេត្ត ទាំងពីរ។

ខែ មករា ឆ្នាំ ២០១២

# ការរៀបចំដី



- សំអាតដីចំការ និង ពីសេស្មៅចេញឱ្យអស់
- ភ្ជួរដី (គោ ឬ គោយន្ត)

# ការរៀបរង

- ទំហំរង១ម៉ែត្រ (សូមមើលរូបភាព)ចន្លោះពីរងមួយទៅរងមួយមានប្រវែង០,៥ម៉ែត្រ
- កំពស់រង៖

  រដូវប្រាំង ០,២-០,៣ ម៉ែត្រ

  រដូវវស្សា ០,៣-០,៥ ម៉ែត្រ
- ដាក់លាមកសត្វស្ងួត ឬ ដីកំប៉ុស្តិ៍ ក្នុងបរិមាណ ២-៣គីឡូក្រាម ក្នុងផ្ទៃដី១ម៉ែត្រការ៉េ និង ដាក់ជីគីមី អ៊ិន-ប៉េ-កា (២០-២០-១៥, ១៥-១៥-១៥)






រងគ្របចំបើង



រងគ្របប្លាស្ទិច



## ១. ការលើករង

- ភ្ជួរ រាស់ដីឲ្យបានម៉ដល្អ ហើយហាល ឱ្យបានពី១០ទៅ១៥ថ្ងៃ
- លើករងដាំ:
  - ទទឹង: ១ ម៉ែត្រ និងបណ្តោយទៅតាមលទ្ធភាពដី តែមិនគួរឲ្យលើពី ១៥ ម៉ែត្រ ដែលធ្វើឲ្យពិបាកក្នុងការថែទាំដូចជាស្រោចទឹកដក ស្មៅជាដើម
  - កំពស់: នៅរដូវប្រាំង២០-៣០សង់ទីម៉ែត្រ និង នៅរដូវវស្សា ពី៣០-៥០ សង់ទីម៉ែត្រ
  - ដាក់លាមកសត្វស្ងួត រឺ ជីកំប៉ុស្តិ៍ ក្នុងបរិមាណ ២-៣គីឡូក្រាម ក្នុងផ្ទៃដី១ម៉ែត្រការ៉េ និងដាក់ជីគីមី អិន-ប៉េ-កា (២០-២០-១៥,១៥-១៥-១៥) (សូមមើលតារាងការប្រើប្រាស់ជី) លាយច្របល់ជាមួយដី
  - គ្របរងដាំ: ធ្វើបានពីរប្រភេទដើម្បីទប់ស្កាត់ការហូរច្រោះរង ការពារសំណើមដី កាត់បន្ថយការដុះស្មៅ៖

### ក. ធ្វើរងប្រើប្លាស្ទិចគ្របដី



១.ធ្វើបន្ទះឬស្សីសំរាប់ខ្ទាស់





២.ដោតកន្លាស់ឬស្សីនៅខាងគល់និងខាងចុងរង



៣.លាតសន្ទឹងដុំប្លាស្ទិច



៤. ដោតបន្ទះឬស្សីនៅសងខាងជើងរងប្រវែងពី១៥-២០សង់ទីម៉ែត្រ



៥.យកដីសង្កត់ជើងរងសងខាង

៦.ចោះរណ្តៅ ដោយប្រើកំប៉ុងក្តៅ



ចំណាំ៖

- ប្រើវត្ថុទាំងឡាយណាដែលអាចរកបាន (ដូចជាឬស្សី ឬ ធាងត្នោត)។ គ្របប្លាស្ទិចឱ្យតឹងល្អរាបស្មើជាប់នឹងផ្ទៃរងដី (តែកុំតឹងខ្លាំងអាចរហែក រយៈប្លាស្ទិច) ជៀសវាងកុំឱ្យមានប្រលោះខ្យល់នៅខាងក្នុងអាចបង្កឱ្យរលាកកូនដំណាំបាន។
- ក្នុងករណីដីមានក្រួសធំៗនៅតាមរងលើកសំរាប់ដាំ ដែលជាហេតុបណ្តាលឲ្យប្លាស្ទិចរហែកនោះ យើងអាចយកចំបើង ឬ អង្កាមគ្របពីលើប្លាស្ទិច។

## ខ. លើករងប្រើចំបើងគ្រប



ដាក់ជីទ្រាប់បាតហើយស្រោចទឹក ទើបគ្របចំបើង

### គំរូការរៀបចំរងដាំ (អាចធ្វើបានពីររបៀប)



## ២. ការធ្វើរានបណ្ដុះ

- ដំបូលសំរាប់គ្របរាន: កំពស់ ១,៨ទៅ ២ ម៉ែត្រ ដើម្បីងាយស្រួលចេញចូលថែទាំ
- កំពស់រាន: ០,៥-០,៧ម៉ែត្រពីដី
- ទទឹងរាន: ០,៨ -១ម៉ែត្រ
- មានដំបូលការពារទឹកភ្លៀងនិងសំណាញ់ ការពារពន្លឺថ្ងៃ (ជាការប្រសើរប្រើសំណាញ់មាន ពណ៌បៃតង)
- មានសំណាញ់ការពារសត្វល្អិត។




**ធ្វើបែបនេះ៖ កាត់បន្ថយការលួយកូន គ្រាប់ដុះបានល្អ និងការពារបានពីការឆ្លងជម្ងឺពីសត្វល្អិតចង្រៃ។**

## ៣. ការរៀបចំដីបណ្ដុះ

- យកដីមានជីជាតិ ១ ភាគលាយជាមួយជីលាមកគោស្ងួត ឬជីកំប៉ុស្ដិ៍ ២ ភាគ និងផេះអង្កាម២-៣ភាគ (ផេះអង្កាមត្រូវត្រាំទឹករយៈពេល៣-៤យប់)
- យកល្បាយដែលបានលាយច្របល់ហើយទៅលីងរហូតក្ដៅសព្វទាំងអស់






**ផលប្រយោជន៍នៃការលាយល្បាយដី គឺ**

- គ្រាប់ងាយដុះ ឫសដុះលូតលាស់ល្អ
- កូនបន្លែស្រូបយកជីជាតិបានគ្រប់គ្រាន់
- សម្លាប់មេរោគ(ជម្ងឺ) ដែលបង្កឲ្យកូនបន្លែរលួយ
- សម្លាប់គ្រាប់ស្មៅចង្រៃដែលដុះដណ្ដើមយកជីជាតិពីកូនបន្លែ
- សម្លាប់ពង និង សត្វល្អិតចង្រៃក្នុងដីដែលបំផ្លាញគ្រាប់បន្លែ

- យកដីដែលលីងហើយទុកឱ្យត្រជាក់សិន ទើបយកដាក់ក្នុងកន្ទោង ឬ ថាសបណ្តុះ





## ៤. ការរៀបចំបណ្តុះកូនបន្លែ

- ត្រូវរៀបចំបណ្តុះកូនបន្លែ ព្រមពេលជាមួយគ្នានឹងការរៀបចំដីដាំ
- ការបណ្តុះកូនបន្លែមានពីររបៀបៈ





### ក. បណ្តុះគ្រាប់ជាមុន

- យកគ្រាប់ដាក់ពង្រាយក្នុងក្រណាត់ស្បៃជក់ទឹករុំគ្រាប់ឲ្យហប់ល្អ
- ស្រោច ទឹកជារៀងរាល់ថ្ងៃឲ្យក្រណាត់ស្បៃសើម ហើយដាក់ទីកន្លែងហប់មានកំដៅ
- ផ្អាប់គ្រាប់ចំនួន១-២ យប់
- ជ្រើសរើសយកគ្រាប់បែកមាត់ដាក់១គ្រាប់ ក្នុង១កន្ទោង ឬ ១ រន្ធថាសបណ្តុះ
- ដាក់គ្រាប់ជំរៅ ១ស.ម បើដាក់គ្រាប់ជ្រៅពេក ឬ រាក់ពេក អាចធ្វើឲ្យគ្រាប់មិនដុះបាន
- រោយដីស្តើងៗពីលើគ្រាប់
- ស្រោចទឹករៀងរាល់ពេលព្រឹកឲ្យជោគ (អាច១-២ដងក្នុង១ថ្ងៃអាស្រ័យតាមស្ថានភាពដី) បើសិនដីស្ងួតពេក អាចធ្វើឲ្យគ្រាប់មិនដុះ។

### ខ. ដាក់គ្រាប់បណ្តុះដោយផ្ទាល់ក្នុងថាសបណ្តុះ ឬ កន្ទោង



- យកគ្រាប់ស្ងួតចំនួន១គ្រាប់ដាក់បណ្តុះផ្ទាល់ ក្នុង១កន្ទោង ឬ ១ រន្ធថាស បណ្តុះ។
- ដាក់គ្រាប់ជំរៅ ១ស.ម បើដាក់គ្រាប់ជ្រៅពេក ឬ រាក់ពេក អាចធ្វើឲ្យគ្រាប់មិនដុះបាន
- រោយដីស្តើងៗពីលើគ្រាប់
- ស្រោចទឹករៀងរាល់ពេលព្រឹកឲ្យជោគ (អាច១-២ដង ក្នុង១ថ្ងៃអាស្រ័យតាមស្ថានភាពដី) បើសិនដីស្ងួត ពេកអាចធ្វើឲ្យគ្រាប់មិនដុះ។

- យកថាស ឬ កន្ទោងដែលបានដាក់គ្រាប់ហើយ ទៅដាក់លើរាន ដែលមានសំណាញ់សត្វល្អិតការពារ។



កូនម្ទេសបណ្ដុះក្នុងកន្ទោងស្លឹកចេក



កូនម្ទេសបណ្ដុះក្នុងថាសបណ្ដុះ

## ៥. ការដាំកូនម្ទេស

- បន្ទាប់ពីកូនម្ទេសដុះបានអាយុ២២-២៥ថ្ងៃ (កូនម្ទេសមានស្លឹក ៤-៥សន្លឹក) អាចយកទៅដាំបាន
- ត្រូវពង្រឹងកូនម្ទេសចំនួន ៣-៥ថ្ងៃមុនយកកូនទៅដាំ (ដាក់កូនម្ទេសឲ្យត្រូវពន្លឺថ្ងៃ និងកាត់បន្ថយការស្រោចទឹក)
- បញ្ចូលទឹកតាមប្រឡោះរងនៅពេលព្រឹក (ប្រសើរបំផុតសំរាប់រងដាំដោយគ្របប្លាស្ទិចប៉ុណ្ណោះ)



ដាក់កូនម្ទេសឲ្យត្រូវពន្លឺថ្ងៃ៣-៤ថ្ងៃមុនយកដាំ



បញ្ចូលទឹកតាមរងនៅពេលព្រឹក  ដាំកូនដំណាំនៅពេលរសៀល

- ដកកូនម្ទេសថ្នមៗចេញពីថាសបណ្ដុះ ដោយយកដៃម្ខាងរុញបាតថាសឡើងលើ ហើយដៃម្ខាងទាញគល់កូនម្ទេសដកចេញពីថាស។

កូនម្ទេសដែលដកពី ថាសបណ្ដុះ





- ដាក់ថ្នាំពុលកសិកម្ម ដាយណូតឺហ្វូយ៉ាន់ (Dinotefuran) មុនពេលដាំ ២ក្រាម/រណ្ដៅ។ យើងអាចដាក់មុន ឬ ក្រោយពេលដាំ (យ៉ាងយូរ៧ថ្ងៃបន្ទាប់ពីដាំ) ដើម្បីការពារសត្វល្អិតចង្រៃបំផ្លាញដំណាំដូចជាពពួកសត្វល្អិតជញ្ជក់ (រុយស ចៃ ទ្រីប..)



- ដាំកូនម្ទេសដាក់ត្រឹមដីកំណើត (ដីបណ្ដុះ)






បំពង់បឺតអាចប្រើសំរាប់ទប់ដើមម្ទេសទើបដាំ និងការពារចង្រិត ឬ សត្វចង្រៃផ្សេងៗកាត់ដើម




## ៦. ការថែទាំ

### ៦.១. ការដាក់ជី

#### ក. ទីតាំងដាក់ជីបំប៉ន

- រងគ្របប្លាស្ទិច ឬ គ្របចំបើង ត្រូវយកឈើបុករណ្ដៅសងខាងគុម្ព ទើបដាក់ជី
- ដាំកូនបន្លែបានរយៈពេល២ អាទិត្យ ត្រូវដាក់ជីចំងាយ ៥ស.ម ពីគល់
- ដាំកូនបានរយៈពេល៤អាទិត្យ ត្រូវដាក់ជីចំងាយ ១០ ស.ម ពីគល់
- ដាំកូនបានលើសពី៦អាទិត្យ ត្រូវដាក់ជីនៅចន្លោះកណ្ដាលពីគុម្ពមួយទៅគុម្ពមួយ។

### ខ. ពេលវេលាដាក់ជីបំប៉ន




- ដាក់ជីបំប៉នឱ្យបានទៀងទាត់ចន្លោះពី៧-១៥ថ្ងៃម្ដង បន្ទាប់ពីដាំកូនបន្លែហើយ គឺអាស្រ័យតាមប្រភេទដី។ ចំពោះដីខ្សាច់ត្រូវដាក់ជីឱ្យបានញឹកញាប់តែបរិមាណតិចជាងដីមានល្បាយច្រើនជាងខ្សាច់។
- មិនត្រូវដាក់ជីនៅពេលថ្ងៃក្ដៅដើម្បីជៀសវាងការប៉ះពន្លឺថ្ងៃក្ដៅខ្លាំងធ្វើឱ្យជីភាយហើយឆួលខ្លោចស្លឹក ដើម
- ស្រោចទឹកភ្លាមបន្ទាប់ពីដាក់ជីហើយ (ជៀសវាងដាក់ជីគីមីនៅពេលថ្ងៃក្ដៅ វាបង្កឱ្យឆួលខ្លោចដំណាំ)

### គ. បរិមាណជីសំរាប់ប្រើ

| ចំនួនថ្ងៃបន្ទាប់ពីដាំ | ប្រភេទជី | បរិមាណជី | កន្លែងដាក់ជី |
|---|---|---|---|
| មុនដាំ ៥ថ្ងៃ ឬពេលដាំ | ជីអិន ប៉េ កា (២០.២០.១៥ ឬ ១៥.១៥.១៥) | ១០ក្រាម/ដើម | ទ្រាប់បាត |
| | ជីសរីរាង្គ | ២គីឡូក្រាម/ដើម | ទ្រាប់បាត |
| ៩ | ជីអិន ប៉េ កា (២០.២០.១៥ ឬ ១៥.១៥.១៥) | ៥ក្រាម/ដើម | បំប៉ន |
| | ជីអាសូត (៤៦.០.០) | ៥ក្រាម/ដើម | បំប៉ន |
| ២៣ | ជីអិន ប៉េ កា (២០.២០.១៥ ឬ ១៥.១៥.១៥) | ៥ក្រាម/ដើម | បំប៉ន |
| | ជីអាសូត (៤៦.០.០) | ៥ក្រាម/ដើម | បំប៉ន |
| ៣៧ | ជី អិន ប៉េ (១៦.២០.០) ឬ ជី អិន ប៉េ កា (២០.២០.១២) | ៥ក្រាម/ដើម | បំប៉ន |
| | ជី ប៉ូតាស្យូម (០.០.៦០) | ១០ក្រាម/ដើម | បំប៉ន |
| ៥១ | ជីអិន ប៉េ កា (២០.២០.១៥ ឬ ១៥.១៥.១៥) | ៥ក្រាម/ដើម | បំប៉ន |
| ៦៥ | ជី អិន ប៉េ (១៦.២០.០) ឬ ជី អិន ប៉េ កា (២០.២០.១២) | ៥ក្រាម/ដើម | បំប៉ន |
| | ជី ប៉ូតាស្យូម (០.០.៦០) | ១០ក្រាម/ដើម | បំប៉ន |
| ៧៩ | ជីអិន ប៉េ កា (២០.២០.១៥ ឬ ១៥.១៥.១៥) | ៥ក្រាម/ដើម | បំប៉ន |
| ៨៦ | ជី ប៉ូតាស្យូម (០.០.៦០) | ៥ក្រាម/ដើម | បំប៉ន |
| ៩៣ | ជីអិន ប៉េ កា (២០.២០.១៥ ឬ ១៥.១៥.១៥) | ៥ក្រាម/ដើម | បំប៉ន |
| ១០៣ | ជីអិន ប៉េ កា (២០.២០.១៥ ឬ ១៥.១៥.១៥) | ៥ក្រាម/ដើម | បំប៉ន |

**ចំណាំ:**

- ស្រោចជីបំប៉នស្លឹក បន្ទាប់ពីដាំកូនបាន៧ថ្ងៃ រហូតពេលចាប់ផ្តើបចេញផ្កាដំបូង រៀងរាល់៧ថ្ងៃម្តង
- បាញ់ជីបំប៉នផ្លែផ្កា បន្ទាប់ពីម្ទេសចាប់ផ្តើមចេញផ្កាដំបូង រៀងរាល់៧ថ្ងៃម្តង
- ដាក់ជីទ្រាប់បាតត្រូវដាក់ចំងាយ ពី ៥ទៅ១៥សង់ទីម៉ែត្រពីគល់ម្ទេស។ លប់ដីពីលើ បន្ទាប់ពីដាក់ជីហើយ
- ដី១០ក្រាម (ប្រហាក់ប្រហែល ១ស្លាបព្រាបាយស្មើ) និង ដី៥ក្រាម (ប្រហាក់ប្រហែល កន្លះស្លាបព្រាបាយ)
- បរិមាណជីដែលដាក់ខាងលើនេះអាស្រ័យទៅតាមស្ថានភាពលូតលាស់ដំណាំ

## ៦.២. ការដោតទំរ និង ការតាក់តែងមែក

- ត្រូវដោតទ្រើងឱ្យរួចរាល់បន្ទាប់ពីដាំកូនម្ទេសហើយ បាន២អាទិត្យ
- ការដោតទ្រើងតាមរបៀបផ្សេងៗគ្នា ដែលអាចធ្វើបាន ដើម្បីទប់ដើម មែក ធ្លាក់មកលើដី
- កាត់ខ្នែងផ្នែកខាងក្រោម ដើម្បីឱ្យមានខ្យល់ និងពន្លឺចេញចូលបានគ្រប់គ្រាន់


បន្ទាប់ពីដាំហើយ ត្រូវចងកូនម្ទេសនឹងបង្គោល ឬ ខ្សែទំរ




## ៦.៣. ការស្រោចទឹក

- បន្ទាប់ពីដាំកូនលើរងរហូតដល់២អាទិត្យ ត្រូវស្រោចទឹកកូនម្ទេសរៀងរាល់ថ្ងៃដើម្បីឲ្យកូនម្ទេសដុះឫសបានរឹងមាំ
- កុំទុកឱ្យដីស្ងួតរហូតដល់៣ថ្ងៃ ជាពិសេសក្នុងពេលម្ទេសចេញផ្កា និងផ្លែ
- ស្រោចទឹកតាមប្រលោះរង។


ស្រោចទឹកតាមប្រលោះរង

# ៧. ការគ្រប់គ្រងជម្ងឺ និង សត្វល្អិតចង្រៃ

## ៧.១. ជម្ងឺអង់ត្រាក់ណូស

ជម្ងឺនេះច្រើនកើតមាននៅពេលចាប់ផ្តើមប្រមូលផ្លែម្ទេស។ វាកើតមាន នៅលើ ផ្លែទុំ ឬ ផ្លែខ្ចី។ ជម្ងឺនេះកើតមានដោយសារប្រើគ្រាប់មានជាប់ជម្ងឺនេះ ឬ ឆ្លងពីកាកសំណល់ដំណាំដែលមានជម្ងឺនេះនៅក្នុងចំការ។ ការស្រោចទឹកពីលើដើម មានភ្លៀង និងមានធ្លាក់សន្សើមរយៈពេលយូរ គឺជាលក្ខខណ្ឌសមស្របសំរាប់ជម្ងឺ រីករាលដាលលឿន។

**វិធីការពារ**

- ដំណាំគ្រាប់ពូជមានគុណភាព
- ដាំដំណាំឆ្លាស់
- ប្រមូលផ្លែស្លឹក យកទៅកប់ចោល

- បាញ់ថ្នាំផ្សិតរវាង ៧-១០ថ្ងៃម្តងពីខាងក្រោមស្លឹក និង ខាងលើស្លឹក នៅពេលថ្ងៃល្ងាច។ យើងអាចជ្រើសរើសយកថ្នាំផ្សិត ខាងក្រោមដែលមាននៅលើទីផ្សារបាញ់ឆ្លាស់គ្នា។ ថ្នាំពុលកសិកម្មសំរាប់កំចាត់ជម្ងឺពពួកផ្សិតមានដូចជា:
  - ម៉ងកូហ្សេប លាយជាមួយមេតាឡាក់ស៊ីល (Mancozeb + metalaxyl) ឬ
  - អាហ្សូហ្សុីនស្រូប៊ីន (Azoxystrobin) ឬ ក្លរ៉ូថាឡូនីល (Chlorothalonil) ឬ កាប់តែន (Captan)





## ៧.២. ជម្ងឺបាក់តេរីអុច ឬ ជម្ងឺច្រេះ




ជម្ងឺនេះ កើតមាននៅលើស្លឹក ទងស្លឹក ផ្លែ និង ដើម។ ជម្ងឺនេះបណ្តាលមកពី ប្រើគ្រាប់ពូជមានមេរោគ ឆ្លងកាកសំណល់បន្លែមាន ជម្ងឺក្នុងចំការ ស្រោចទឹកពីលើប៉ះស្លឹក ដើម មានសន្សើម និង ភ្លៀង ធ្លាក់ច្រើន និង សីតុណ្ហភាពខ្ពស់។

**វិធីការពារ**

- ដាំពូជម្ទេសមានគុណភាពខ្ពស់ គ្មានជាប់ជម្ងឺនេះ និងជ្រើសរើសយកតែកូនម្ទេសដែលគ្មានជម្ងឺនេះទៅដាំ
- ប្រមូលផ្លែ ស្លឹក ដើមមានជម្ងឺទៅកប់
- បាញ់ថ្នាំផ្សិត រវាង ៧ -១០ថ្ងៃពីខាងក្រោមស្លឹក និងខាងលើស្លឹកនៅពេលថ្ងៃល្ងាច។ យើងអាចជ្រើសរើសយកថ្នាំផ្សិតខាងក្រោម ដែលមានលក់នៅតាមទីផ្សារ មកប្រើបាញ់ឆ្លាស់គ្នា។ ថ្នាំពុលកសិកម្មសំរាប់កំចាត់ជម្ងឺបង្កពីផ្សិតដើម្បីកាត់បន្ថយជម្ងឺ មានដូចជា:
  - ម៉ង់កូហ្សេប លាយជាមួយមេតាឡាក់ស៊ីល **(Mancozeb + metalaxyl)** ឬ
  - បាញ់ថ្នាំផ្សិតកូភើ **(Copper)**

## ៧.៣. ជម្ងឺស្រពោន

ជម្ងឺនេះចាប់ផ្តើមស្រពោនកើតចេញពីស្លឹកនៅខាងក្រោម (កូន ម្ទេសស្រពោនពីស្លឹកនៅផ្នែកខាងលើ) និងជាបន្តដើមម្ទេសចាប់ផ្តើមស្រពោនទាំងអស់។ បាក់តេរីបង្ករជម្ងឺនេះរស់នៅក្នុងដី បានយ៉ាងយូរ។ នៅពេលណាដើមមានសំណើមខ្ពស់ ហើយបរិយាកាសដែលមានសីតុណ្ហភាពខ្ពស់ ជម្ងឺនេះរីករាលដាលបានយ៉ាងលឿន។

## វិធីការពារ



- ជ្រើសរើសដីបណ្តុះដែលគ្មានជម្ងឺនេះ ជ្រើសរើសពូជធន់នឹងជម្ងឺនេះ។
- ដាំដំណាំឆ្លាស់ (ដំដាំណាំមិនមែនគ្រួសារ/អំបូរជាមួយម្ទេស)។
- ដាំកូនម្ទេសដែលមានឫសនៅល្អ (ឫសមិនដាច់)
- ប្រមូលដំណាំដែលកើតជម្ងឺដុតចោល
- រងដាំដែលកើតជម្ងឺស្រពោន មិនត្រូវបង្ហូរទឹកចេញទៅរងផ្សេងទៀតទេ ពីព្រោះវាអាចនាំជម្ងឺទៅរងផ្សេងទៀតបាន។

## ៧.៤. រុយស

ត្រូវការពេលផ្ទេរវីរ៉ុសទៅដំណាំផ្សេងទៀត នៅពេលដែលវាជញ្ជក់ដំណាំ។ វាជញ្ជក់រុក្ខរស ដំណាំបានច្រើនប្រភេទ។



មេរុយស



រោគសញ្ញាដំណាំម្ទេសដែល មានជម្ងឺដោយសាររុយសជាអ្នកចម្លងជម្ងឺពីដំណាំផ្សេងមក

## វិធីការពារ និង ការកំចាត់

- ប្រើអន្ទាក់ពណ៌លឿង និងប្រើប្លាស្ទិចគ្របដីដើម្បីកាត់បន្ថយចំនួនពពួក រុយ ស
- ប្រើថ្នាំពុលកសិកម្ម ដាយណូតឺហ្វូយរ៉ាន់ (Dinotefuran) ២ក្រាម/រណ្តៅ។ យើងអាចដាក់មុន ឬ ក្រោយពេលដាំ (យ៉ាងយូរ៧ថ្ងៃបន្ទាប់ពីដាំ) ដើម្បីការពារសត្វល្អិតចង្រៃបំផ្លាញដំណាំដូចជាពពួកសត្វល្អិតជញ្ជក់រុយស និងសត្វល្អិតជញ្ជក់ផ្សេងៗទៀត
- បាញ់ថ្នាំពុលកសិកម្មដូចជាៈ ថ្នាំ អ៊ីមីដាក្លូព្រីដ (Imidacloprid) ថ្នាំ ឌីយ៉ាស៊ីណុង (Diazinon) ថ្នាំអាបាមិចទីន

### របៀបធ្វើអន្ទាក់ចាប់រុយស




ការស្អិតចាប់សត្វល្អិត





លាបការស្អិតពីលើអន្ទាក់ប្លាស្ទិចពណ៌លឿង



ដាក់អន្ទាក់ចន្លោះពី៧ទៅ១០ម៉ែត្រ

សំគាល់៖

- មិនត្រូវយកថ្នាំពុលកសិកម្មលាយចូលគ្នាច្រើនមុខសំរាប់បាញ់ទេ (ថ្នាំអាចមានប្រតិកម្មជាមួយគ្នា បណ្តាលឲ្យពុំមានប្រសិទ្ធិភាព)
- ត្រូវជ្រើសរើសយកក្បាលបាញ់ទុយយោមានលក្ខណៈសាចល្អ ទើបថ្នាំនៅជាប់នឹងដើមស្លឹកបន្លែ
- ត្រូវប្រើទឹកស្អិតលាយជាមួយថ្នាំនៅពេលបាញ់ថ្នាំ
- ត្រូវបាញ់នៅខាងលើនិងខាងក្រោមផ្ទៃស្លឹក តាមត្រួយស្លឹកដើមឱ្យសព្វ
- បាញ់ថ្នាំពុលកសិកម្មនៅពេលថ្ងៃល្ងាច

## ៨. បច្ចេកទេសមុន និង ក្រោយប្រមូលផល

- ផ្លែអាចបេះទៅតាមតំរូវការទីផ្សារ
- បេះផ្លែនៅពេលព្រឹក
- សំភារៈដាក់ផ្លែត្រូវមានផ្ទៃរលោង
- ជ្រើសរើសម្ទេសដែលល្អដាច់គេ ដោយឡែកពីផ្លែម្ទេសដែលមានជម្ងឺ ឬ សត្វល្អិតបំផ្លាញ។



ម្ទេសទើបប្រមូលផល មិនទាន់ធ្វើចំណាត់ថ្នាក់





ម្ទេសបានធ្វើចំណាត់ថ្នាក់ហើយ



ច្រកម្ទេសនៅក្នុងថង់ប្លាស្ទិចចោះរន្ធតូចៗ ដើម្បីឲ្យមានខ្យល់ចេញចូល កុំឱ្យស្អោកផ្លែ



EAST-WEST SEED INTERNATIONAL
F1 HYBRID
Hot pepper
Demon